## កត់ទុកកាលបរិច្ឆេទដើម្បីចាក់វ៉ាក់សាំង

វាជាការសំខាន់ដើម្បីធ្វើឱ្យប្រាកដថា ការចាក់វ៉ាក់សាំងត្រូវបានផ្ដល់ឱ្យទាន់ពេលវេលា ដើម្បីឱ្យទារកបានទទួលកិច្ចការពារទាន់ពេល និងមិនមានហានិភ័យនៃការឆ្លងជំងឺធ្ងន់ធ្ងរដែលអាចការពារបាន។




សូមពិនិត្យគម្រោងចាក់ថ្នាំបង្ការរោគ រដ្ឋញូវសៅវែល ដើម្បីឱ្យបានដឹងថាពេលណាកូនរបស់អ្នកនឹងដល់ពេលកំណត់ចាក់វ៉ាក់សាំងបន្ទាប់ នៅតាមគេហទំព័រ health.nsw.gov.au/vaccinate

## កំណត់ត្រាសុខភាពផ្ទាល់ខ្លួនរបស់ខ្ញុំ (សៀវភៅពណ៌ខៀវ)

វាជាការសំខាន់ដែលត្រូវយកសៀវភៅពណ៌ខៀវរបស់កូនអ្នក ទៅកាន់ការណាត់ជួបនីមួយៗដើម្បីឱ្យវេជ្ជបណ្ឌិត/គិលានុបដ្ឋាក កត់ត្រាការចាក់វ៉ាក់សាំងរបស់កូនអ្នក។




## ព័ត៌មានបន្ថែម

### ក្រសួងសុខាភិបាល រដ្ឋញូវសៅវែល

health.nsw.gov.au/immunisation

### ក្រសួងសុខាភិបាល រដ្ឋាភិបាលអូស្ត្រាលី

health.gov.au/health-topics/immunisation

### MumBubVax

mumbubvax.org.au/Hepatitis-B-vaccine

### សន្លឹកព័ត៌មានរដ្ឋញូវសៅវែល ស្ដីពីជំងឺរលាកថ្លើមប្រភេទ B

health.nsw.gov.au/Infectious/factsheets/Pages/Hepatitis_B.aspx

### បញ្ជីចាក់ថ្នាំបង្ការរោគអូស្ត្រាលី

servicesaustralia.gov.au/individuals/services/medicare/australian-immunisation-register

ខែកញ្ញា ឆ្នាំ 2021 © NSW Health. SHPN (HP NSW) 210887-13.

NSW Health

# ការចាក់វ៉ាក់សាំងការពារជំងឺរលាកថ្លើមប្រភេទ B

## សម្រាប់ទារកទើបនឹងកើតរបស់អ្នក



## ជំងឺរលាកថ្លើមប្រភេទ B

ជំងឺរលាកថ្លើមប្រភេទ B អាចបណ្ដាលឱ្យកើតជំងឺថ្លើមដ៏យូរអង្វែង ដូចជារោគក្រិនថ្លើម និងជំងឺមហារីកជាដើម។ ទារកដែលឆ្លងជំងឺរលាកថ្លើមប្រភេទ B មានលទ្ធភាព 90 ភាគរយក្នុងការកើតជំងឺឆ្លងរ៉ាំរ៉ៃដ៏យូរអង្វែង។

ជំងឺរលាកថ្លើមប្រភេទ B គឺឆ្លងខ្លាំងណាស់ ហើយអាចឆ្លងរាលដាលយ៉ាងងាយស្រួលតាមរយៈ៖

- ម្ដាយដែលឆ្លងរោគ ចម្លងទៅឱ្យទារករបស់គេនៅពេលកើតមក
- ស្បែកដាច់រហែក ឬមុតដោយវត្ថុមិនស្អាតដូចជាម្ជុល និងកាំបិតកោរជាដើម
- ប៉ះពាល់ផ្ទាល់រាងឈាមរបស់អ្នកដែលកើតរោគនេះ និងមុខរបួសចំហ ឧទាហរណ៍ ការដាច់រលាត់ ឬមុតស្បែក
- រួមភេទជាមួយអ្នកដែលឆ្លងជំងឺ។

## ការធ្វើតេស្តក្នុងពេលមានផ្ទៃពោះ

ស្ត្រីទាំងអស់គួរតែធ្វើតេស្តរកមើលការឆ្លងជំងឺរលាកថ្លើមប្រភេទ B ក្នុងអំឡុងពេលពិនិត្យផ្ទៃពោះជាប្រចាំ។ ប្រសិនបើជាតេស្តវិជ្ជមាន ទារកនឹងត្រូវការការព្យាបាលដើម្បីការពារការឆ្លង និងហានិភ័យនៃជំងឺថ្លើមរ៉ាំរ៉ៃ។ ការព្យាបាលក៏អាចត្រូវបានណែនាំសម្រាប់ម្ដាយផងដែរ។

## វិធានការការពារ

វ៉ាក់សាំងការពារជំងឺរលាកថ្លើមប្រភេទ B ត្រូវបានប្រើនៅក្នុងប្រទេសអូស្ត្រាលីចាប់តាំងពីដើមទស្សវត្សរ៍ឆ្នាំ 1980 មកម្លេះ ហើយការចាក់វ៉ាក់សាំង គឺជាមធ្យោបាយល្អបំផុតដើម្បីការពារជំងឺនេះ។

## វ៉ាក់សាំងការពារជំងឺរលាកថ្លើមប្រភេទ B សម្រាប់ទារកទើបនឹងកើត

ទារកទើបនឹងកើតទាំងអស់ ត្រូវបានផ្ដល់វ៉ាក់សាំងការពារជំងឺរលាកថ្លើមប្រភេទ B នៅពេលកើតមកដើម្បី៖

- ការពារការឆ្លងរាលដាលនៃជំងឺ ពីម្ដាយដែលកើតរោគទៅទារករបស់គេ។ ពេលខ្លះ ម្ដាយអាចមិនដឹងថាខ្លួនមានជំងឺនេះឡើយ និង
- បង្ការការឆ្លងរាលដាលនៃជំងឺ ក្នុងខែដំបូងនៃជីវិតទារកពីអ្នកឆ្លងមេរោគនេះដែលរស់នៅក្នុងផ្ទះជាមួយគ្នា ឬអ្នកឯទៀត ដែលអាចឆ្លងមេរោគនេះ។

## គម្រោងចាក់វ៉ាក់សាំងការពារជំងឺរលាកថ្លើមប្រភេទ B

នេះត្រូវបានណែនាំថា វ៉ាក់សាំងការពារជំងឺរលាកថ្លើមប្រភេទ B មួយដូស ត្រូវបានផ្ដល់ឱ្យទារករបស់អ្នកនៅពេលកើតមក ឬក្នុងរយៈពេល 7 ថ្ងៃដំបូងនៃជីវិតរបស់ទារក បន្ទាប់មកត្រូវផ្ដល់វ៉ាក់សាំងការពារជំងឺរលាកថ្លើមប្រភេទ B បីដូសថែមទៀត នៅអាយុ 6 សប្ដាហ៍ 4 ខែ និង 6 ខែ។

## សុវត្ថិភាពនៃវ៉ាក់សាំងការពារជំងឺរលាកថ្លើមប្រភេទ B

បទពិសោធន៍ទូលំទូលាយបង្ហាញថា វ៉ាក់សាំងការពារជំងឺរលាកថ្លើមប្រភេទ B មានសុវត្ថិភាព និងអនុគ្រោះបានល្អចំពោះទារកទើបនឹងកើត។ ផលប៉ះពាល់បន្ទាប់បន្សំទូទៅបំផុតនៃវ៉ាក់សាំងការពារជំងឺរលាកថ្លើមប្រភេទ B គឺមានតិចតួច ហើយរួមមានការឡើងក្រហម និងការហើមនៅត្រង់កន្លែងចាក់ថ្នាំ។ វ៉ាក់សាំងការពារជំងឺរលាកថ្លើមប្រភេទ B មិនរំខានដល់ការបំបៅកូនដោយទឹកដោះម្ដាយឡើយ។

## ការព្យាបាលទារកកើតពីម្ដាយដែលមានជំងឺរលាកថ្លើមប្រភេទ B វិជ្ជមាន

ទន្ទឹមនឹងការផ្ដល់នូវវ៉ាក់សាំងការពារជំងឺរលាកថ្លើមប្រភេទ B មួយដូសនៅពេលទារកកើតមក ទារកដែលកើតពីម្ដាយមានជំងឺរលាកថ្លើមប្រភេទ B នឹងត្រូវបានផ្ដល់នូវថ្នាំពេទ្យមួយហៅថា “ជំងឺរលាកថ្លើមប្រភេទ B អ៊ីមុយណូក្លូប៊ុយលីន” (immunoglobulin) ក្នុងរយៈពេល១២ម៉ោងនៅពេលកើតមក ដើម្បីផ្ដល់នូវកិច្ចការពារបន្ថែមទៀត។ នេះគឺជាការសំខាន់ដែលត្រូវបំពេញវគ្គចាក់វ៉ាក់សាំងការពារជំងឺរលាកថ្លើមប្រភេទ B ឱ្យបានចប់សព្វគ្រប់សម្រាប់កិច្ចការពារយូរអង្វែង។

## ការធ្វើតេស្តបន្ថែមចំពោះទារកកើតពីម្ដាយដែលមានជំងឺរលាកថ្លើមប្រភេទ B វិជ្ជមាន

ទារកកើតពីម្ដាយដែលមានជំងឺរលាកថ្លើមប្រភេទ B ត្រូវការធ្វើតេស្តឈាម 3 ខែក្រោយពេលបំពេញវគ្គចាក់វ៉ាក់សាំងការពារជំងឺរលាកថ្លើមប្រភេទ B ដើម្បីឆែកមើលថាតើពួកគេបានទទួលការការពារឬក៏អត់។ អ្នក និងវេជ្ជបណ្ឌិតរបស់អ្នកនឹងបានទទួលលិខិតរម្លឹកមួយច្បាប់ ពីក្រសួងសុខាភិបាលរដ្ឋញូវសៅវែល។

